**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៥៦០អ.ក
ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១
សាលក្រមលេខ: ១៣ "ច"
ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ០៨:៣០ ព្រឹក ដោយមានសមាសភាពដូចតទៅ:

## ចៅក្រមជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្តាល

លោក [redacted] ចៅក្រមប្រឹក្សា នៃសាលាដំបូងខេត្តកណ្តាល

លោក [redacted] ចៅក្រមប្រឹក្សា នៃសាលាដំបូងខេត្តកណ្តាល

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអយ្យការអមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

## មេធាវី

មេធាវី [redacted] ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] លីនដា, [redacted] ប្រុសហ៊ឹម, [redacted] ដារ៉ា

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ:៥៦០ អក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ:

១- ឈ្មោះ [redacted] **លីនដា ហៅជ្រូក** ភេទស្រី អាយុ២៨ ឆ្នាំ ជាតិខ្មែរ មុខរបរៈចុងភៅ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តតាកែវ និងទីលំនៅបច្ចុប្បន្ននៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ជាន (រ) ម្តាយឈ្មោះ [redacted] សារឿន (រ) មេម៉ាយ មានកូន០១(មួយ)នាក់ ជានីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ)។

២- ឈ្មោះ [redacted] **ប្រុសហ៊ឹម** ភេទប្រុស អាយុ៣៩ ឆ្នាំ ជាតិខ្មែរ មុខរបរៈនេសាទ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] លី (រ) ម្តាយឈ្មោះ សៈ (រ) ប្រពន្ធឈ្មោះ [redacted] រ៉ូនី មានកូន០៣(បី)នាក់ ជានីតិជន ទោសពីមុខគ្មាន។(ក្នុងឃុំ)

៣- ឈ្មោះ [redacted] **ដារ៉ា** ភេទប្រុស អាយុ៤៣ ឆ្នាំ ជាតិខ្មែរ មុខរបរៈជាងម៉ាស៊ីនត្រជាក់ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សាម៉ុន(ស) ម្តាយឈ្មោះ [redacted] ណារ៉ុន(រ) ប្រពន្ធឈ្មោះ [redacted] រតនា (រ) មានកូន០៤(បួន)នាក់ ជានីតិជន ទោសពីមុខគ្មាន។ (ក្នុងឃុំ)

ក្រឡាបញ្ជី

[redacted]

-ត្រូវជាប់ចោទពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ **តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

## ដំណាលរឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង១៧ និង២០ នាទី កើតឡើងនៅចំណុចរោងទុកចោល ស្ថិតនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលបង្កឡើងដោយជនសង្ស័យ ឈ្មោះ [redacted] លីនដា ហៅ ជ្រូក បានធ្វើសកម្មភាពជួយដូរថ្នាំញៀនប្រភេទម៉ាទឹកកកនៅចំណុចកើតហេតុខាងលើ ដែលថ្នាំញៀនប្រភេទម៉ាទឹកកកទាំងនេះជនសង្ស័យបានឡើងទៅទិញពីបុរសមិនស្គាល់ម្នាក់នៅម្តុំវត្តសន្សំកុសល រាជធានីភ្នំពេញ ម្តងតម្លៃ១លានរៀល យកមករំលែកជាកញ្ចប់តូចៗ សម្រាប់លក់ឱ្យម៉ូយរស់នៅក្នុងភូមិជាមួយគ្នាក្នុងមួយកញ្ចប់តូចតម្លៃ២ម៉ឺនរៀល ហើយពេលលក់អស់ម្តងៗ ជនសង្ស័យចំណេញបានប្រាក់ពីចន្លោះពី៥ទៅ៦ម៉ឺនរៀល គ្រាន់ទុកទិញបាយហូប។ លុះមកដល់ថ្ងៃកើតហេតុ ខណៈពេលសមត្ថកិច្ចកំពុងល្បាតក្នុងភូមិសាស្ត្រខាងលើក៏បានប្រទះជាមួយជនសង្ស័យឈ្មោះ [redacted] លីនដា ហៅជ្រូក និងបក្ខពួកចំនួន២រូបទៀត ឈ្មោះ [redacted] ប្រុសហ៊ីម និងឈ្មោះ [redacted] ដារ៉ា កំពុងធ្វើសកម្មភាពជួញដូរថ្នាំញៀនប្រភេទម៉ាទឹកកក ក្រោយមកសមត្ថកិច្ចក៏ឃាត់ខ្លួនជនសង្ស័យទាំង០៣(បី)នាក់ និងដកហូតថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន១០កញ្ចប់ (ធំ០៣, តូច០៧) ស្មើទម្ងន់២០,១០ក្រាម រួមទាំងសម្ភារៈប្រើថ្នាំញៀនមួយចំនួន បញ្ជូនមកអធិការដ្ឋាននគរបាលក្រុងតាខ្មៅ ដើម្បីចាត់ការតាមនីតិវិធីតែម្តង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

១- យោងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លីនដា ហៅ ជ្រូក, ឈ្មោះ [redacted] ប្រុសហ៊ីម និង ឈ្មោះ [redacted] ដារ៉ា តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងតាមការពិនិត្យឯកសារនានាក្នុងសំណុំរឿង ឃើញថា: ពិតជាមានអង្គហេតុដូចការចោទប្រកាន់របស់តំណាងអយ្យការ ដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ ឈ្មោះ [redacted] លីនដា ហៅជ្រូក , [redacted] ប្រុសហ៊ីម និង [redacted] ដារ៉ា ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ **តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** អាចបញ្ជាក់បានថា គឺពិតជាមានអង្គហេតុដូចការចោទប្រកាន់របស់តំណាងអយ្យការពិតប្រាកដមែន។

២-ជនជាប់ឈ្មោះ [redacted] លីនដា ហៅជ្រូក, [redacted] ប្រុសហ៊ីម និង [redacted] ដារ៉ា ជនជាប់ចោទទាំងបីនាក់ជានីតិជន ហើយជនជាប់ចោទមានស្មារតី និង សមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនចំពោះមុខច្បាប់ ពោលគឺជនជាប់ចោទមិនមានសញ្ញាណាណាមួយដែលបង្ហាញថា ជនជាប់ចោទមានវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ ដែលជាហេតុនាំមិនអោយមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនឡើយ។

[redacted]

៣-អំពើនៃការប្រព្រឹត្តរបស់ជនជាប់ចោទ៖

៣-១ យោងតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] លីនដា ដែលបានឆ្លើយនៅក្នុងនីតិវិធីនៃកិច្ចពិភាក្សាដេញដោលបានឆ្លើយថា៖ ខ្លួនត្រូវសមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ដោយមូលហេតុខ្លួនទើបតែត្រឡប់មកពីទិញថ្នាំនៅភ្នំពេញវិញ ហើយបានអង្គុយលេងនៅរោងគេទុកចោល រួចសមត្ថកិច្ចបានមកដក់ធ្វើការឆែកឆេរខ្លួន ខ្លួនឃើញមានថ្នាំញៀនចំនួន១០កញ្ចប់តែម្តង។ ក្នុងនោះកញ្ចប់ធំចំនួន០៣កញ្ចប់ និងតូចចំនួន០៧កញ្ចប់ នៅក្នុងកាបូបរបស់ខ្លួន។ ថ្នាំញៀនទាំង១០កញ្ចប់នោះខ្លួនទិញក្នុងតម្លៃ១,០០០,០០០៛(មួយលាន)រៀល ពីម៉ូតូឌុបមិនស្គាល់ឈ្មោះ ដើម្បីយកមករំលែកលក់បន្ត។ កន្លងមកខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនរយៈពេល០៦ខែមកហើយ ទើបលើកក្រោយនេះខ្លួនទិញយកមកលក់បន្តក៏ត្រូវសមត្ថកិច្ចចាប់តែម្តង។ សមត្ថកិច្ចបានឆែកឆេរឃើញមានថ្នាំញៀនចំនួន១០កញ្ចប់ គឺកញ្ចប់តូច០៧និងកញ្ចប់ធំចំនួន០៣ ប្រាក់រៀលចំនួន១៣ម៉ឺន ទូរស័ព្ទ០១គ្រឿងម៉ាកOPPO។

៣-២ យោងតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ប្រុសហ៊ីម ដែលបានឆ្លើយនៅក្នុងនីតិវិធីនៃកិច្ចពិភាក្សាដេញដោលបានឆ្លើយថា៖ ខ្លួនពិតជាបានចូលលុយគ្នាទិញថ្នាំញៀនមែន គឺខ្លួនចូល២០ម៉ឺនរៀល ហើយពេលទៅទិញគឺខ្លួនទៅទិញទាំងបីនាក់មានឈ្មោះ [redacted] លីនដា និង [redacted] ដារ៉ា។

ជនជាប់ឈ្មោះ [redacted] លីនដា និង [redacted] ប្រុសហ៊ីម ត្រូវបានតំណាងអយ្យការនិងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះ ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល។ យោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ និងរបាយការណ៍មន្ត្រីនគរបាលយុត្តិធម៌ ដែលបានសន្និដ្ឋានថា៖ ជនជាប់ចោទទាំងពីរឈ្មោះ [redacted] លីនដា និង [redacted] ប្រុសហ៊ីម បានធ្វើសកម្មភាពចូលលុយគ្នាទិញថ្នាំញៀនយកមកជួញដូរពិតប្រាកដមែន។ ដូច្នេះតុលាការយល់ឃើញថាអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] លីនដា និង [redacted] ប្រុសហ៊ីម ដែលមាននៅក្នុងអង្គហេតុខាងលើគឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតប្រាកដមែន។

៣-៣ យោងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ដែលបានឆ្លើយនៅគ្រប់នីតិវិធីបានឆ្លើយថា សមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ដោយមូលហេតុខ្លួនទៅទិញថ្នាំញៀនពីឈ្មោះ [redacted] លីនដា ចំនួន០១ កញ្ចប់តូចតែពុំទាន់បានទិញទេត្រូវសមត្ថកិច្ចបានចុះមកធ្វើការឃាត់ខ្លួនតែម្តង។ ថ្នាំញៀន១០កញ្ចប់នោះជារបស់ឈ្មោះ [redacted] លីនដា ខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] លីនដា ចំនួន២ដងមកហើយ ដោយទិញម្តងក្នុងតម្លៃ ៣ម៉ឺនរៀល។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនជារៀងរាល់ថ្ងៃ។

ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរបញ្ជូនមកធ្វើការជំនុំជម្រះពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ថ្វីត្បិតតែជនជាប់ចោទបានឆ្លើយបដិសេធថាខ្លួនមិនបានចូលលុយគ្នាទិញថ្នាំញៀនយកមកជួញដូរទេ ខ្លួនគ្រាន់តែទិញយកមកប្រើប្រាស់ ចម្លើយរបស់ជនឈ្មោះ [redacted] ដារ៉ា គ្រាន់តែឆ្លើយដោះសារតែប៉ុណ្ណោះ បើយោងតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] លីនដា [redacted] ប្រុសហ៊ីម និងរបាយការណ៍មន្ត្រីនគរបាលយុត្តធម៌មានភាពស៊ីសង្វាក់គ្នា ដែលអាចឱ្យតុលាការជឿបានថាជនឈ្មោះ [redacted] ដារ៉ា ពិតជាជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតប្រាកដមែន។

៤-យោងតាមចំណុចទី៣ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះ ឃើញថា៖ បច្ច័យទាំងនេះ គឺកើតចេញពីអំពើរបស់ជនជាប់ចោទដោយផ្ទាល់ឈ្មោះ [redacted] លីនដា, ឈ្មោះ [redacted] ប្រុសហ៊ីម និងឈ្មោះ [redacted] ដារ៉ា ដែលតម្រូវឱ្យជនជាប់ចោទទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួន។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
31 ខែ 3 ឆ្នាំ 20.22
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner

៥-ធាតុអត្តនោម័តរបស់ជនជាប់ចោទ៖

៥-១ ជនជាប់ចោទឈ្មោះ [redacted] លីនដា ហៅ ជ្រូក និង [redacted] ប្រុសហ៊ីម ៖ តាមចម្លើយរបស់ជនជាប់ចោទនៅគ្រប់ដំណាក់កាលនៃនីតិវិធី គឺជនជាប់ចោទបានសារភាពថាខ្លួនពិតជាបានចូលលុយគ្នាទិញថ្នាំញៀនយកមកលក់ពិតប្រាកដមែន។ ជនជាប់ចោទផ្ទាល់មានការយល់ដឹងពីចរិតគ្រោះថ្នាក់ នៃគ្រឿងញៀន ប៉ុន្តែជនជាប់ចោទនៅតែមានឆន្ទៈក្នុងការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ សកម្មភាពទាំងនេះគឺអាចបញ្ជាក់បានពីការយល់ដឹង និងធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៥-២ ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ៖ បើយោងតាមចម្លើយរបស់ជនជាប់ចោទផ្ទាល់ជនជាប់ចោទបានឆ្លើយបដិសេធថាខ្លួនមិនបានចូលលុយគ្នាជួញដូរថ្នាំញៀនទេ ខ្លួនគ្រាន់តែទិញប្រើប្រាស់ទេ ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា គ្រាន់តែឆ្លើយដោះសារតែប៉ុណ្ណោះ បើតាមចម្លើយឈ្មោះ [redacted] លីនដា និង [redacted] ប្រុសហ៊ីម នៅគ្រប់ដំណាក់កាលនីតិវិធីគឺជនជាប់ចោទបានឆ្លើយថាខ្លួនបានចូលលុយគ្នាទិញថ្នាំញៀនជាមួយឈ្មោះ [redacted] ដារ៉ា ពិតប្រាកដមែន។ ជនជាប់ចោទផ្ទាល់មានការយល់ដឹងពីចរិតគ្រោះថ្នាក់នៃគ្រឿងញៀនប៉ុន្តែជនជាប់ចោទនៅតែមានឆន្ទៈក្នុងការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ សកម្មភាពទាំងនេះគឺអាចបញ្ជាក់បានពីការយល់ដឹង និងធាតុអត្តនោម័តរបស់ជនជាប់ចោទចំពោះអំពើល្មើសរបស់ខ្លួន។

៦-ធាតុនីត្យានុកូល ៖ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] លីនដា ហៅជ្រូក, [redacted] ប្រុសហ៊ីម និងឈ្មោះ [redacted] ដារ៉ា ជាអំពើមួយដែលធ្វើអោយប៉ះពាល់ដល់សុខភាព សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ប៉ះពាល់ដល់សន្តិសុខសង្គម ជាអំពើមួយដែលច្បាប់បញ្ញត្តិចែងថាជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានភាពសុទ្ធនៃគ្រឿងញៀន (២០,១០g×៧៥,៧២%)៖១០០%=**១៥,២១g** ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** គប្បីតុលាការសម្រេចធ្វើការប្រកាសទោសឱ្យជនជាប់ចោទទទួលខុសត្រូវតាមបញ្ញត្តិមាត្រាខាងលើ។

៧-មានធាតុផ្សំនៃបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសទៅលើជនជាប់ចោទ៖ ឈ្មោះ [redacted] លីនដា, [redacted] **ប្រុសហ៊ីម និងឈ្មោះ** [redacted] **ដារ៉ា** ពីបទ៖ ជួយដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ **តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ។

៨-ការសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ក្រោយពីបានធ្វើកិច្ចពិភាក្សាដេញដោលរបស់ជនជាប់ចោទឈ្មោះ [redacted] លីនដា, [redacted] ប្រុសហ៊ីម និងឈ្មោះ [redacted] ដារ៉ា តំណាងអយ្យការនៅតែសម្រេចតម្កល់ការចោទប្រកាន់ទៅដីការសន្និដ្ឋានស្ថាពរលេខៈ ១០៧២ ដក.សព ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់។

៩- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] លីនដា, [redacted] ប្រុសហ៊ីម និងឈ្មោះ [redacted] ដារ៉ា បានសន្និដ្ឋានថា៖ ឆ្លងតាមការពិភាក្សាដេញដោលរួចមកជនជាប់ចោទឈ្មោះ [redacted] លីនដា ហៅជ្រូក និងឈ្មោះ [redacted] ប្រុសហ៊ីម បានសារភាពថាខ្លួនពិតជាបានចូលលុយគ្នាទិញថ្នាំញៀនពីបុរសម្នាក់មិនស្គាល់ឈ្មោះ នៅម្តុំផ្សារដើមថ្កូវ ដើម្បីយកមកលក់បន្ត ពិតប្រាកដមែន ដោយសារតែកត្តាជីវភាព និង ពុំបានរៀនសូត្រខ្ពង់ខ្ពស់ទើបធ្វើឱ្យពួកគាត់ ប្រព្រឹត្តិអំពើខុសច្បាប់បែបនេះ ប៉ុន្តែមកដល់ពេលនេះពួកគាត់បានដឹងកំហុសខ្លួន និងមានការសោកស្តាយជាខ្លាំង ហើយពួកគាត់ជាបង្គោលគ្រួសារ ដែលមានកូនតូចៗ និងឪពុកម្តាយចាស់ជរា ត្រូវការការមើលថែ និងផ្គត់ផ្គង់ជាចាំបាច់ ហេតុដូច្នេះស្នើសុំឱ្យតុលាការមេត្តាផ្តល់នូវស្ថានសម្រាលទោសដល់កូនក្តីខ្លួនផង ដើម្បីឱ្យគាត់ឆាប់បានចេញទៅមើលថែរួមរស់នៅជាមួយគ្រួសារវិញ។ ចំពោះ [redacted] ដារ៉ា គឺគាត់បានឆ្លើយ

[redacted]

ថា គាត់ និងឈ្មោះ [redacted] លីនដា និងឈ្មោះ [redacted] ប្រុសហ៊ីម ពុំដែលស្គាល់គ្នានោះទេ ហើយក៏ពុំធ្លាប់មានទំនាក់ទំនងរកស៊ីជួញដូរគ្រឿងញៀនអ្វីនោះដែរ គ្រាន់តែនៅថ្ងៃកើតហេតុខ្លួនទៅទីនោះដើម្បីទិញគ្រឿងញៀនយកមកប្រើប្រាស់ប៉ុណ្ណោះ ពេលគាត់ទៅដល់មិនទាន់បានទិញគ្រឿងញៀនផង ក៏មានសមត្ថកិច្ចចុះមកឃាត់ខ្លួនតែម្តង។ គាត់បានសារភាពថាគាត់ពិតជាបានប្រើប្រាស់គ្រឿងញៀនពិតប្រាកដមែន ប៉ុន្តែគាត់មិនដែលជួញដូរគ្រឿងញៀននោះទេ។ ដោយយោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា វិមតិសង្ស័យ ជាផលប្រយោជន៍របស់ជនជាប់ចោទ ហេតុដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនបាទស្នើសុំឱ្យតុលាការមេត្តាកែប្រែបទចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

១០- វត្ថុចាប់យករួមមាន៖

១០-១ ម្សៅក្រាមពណ៌សថ្លាសង្ស័យជាសាធាតុញៀន ប្រភេទ(ម៉ាទឹកកក)ចំនួន១០(ដប់)កញ្ចប់ ធំ០៣កញ្ចប់ និងឧបករណ៍ប្រើប្រាស់ចំនួន០១ ដែកកេះ០១ គប្បីតុលាការសម្រេចរឹបអូសបំផ្លាញចោល ។

១០-២ ម៉ូតូចំនួន០១(មួយ)គ្រឿង ម៉ាក់គ្រីអង្គរពណ៌ក្រហម ស្លាកលេខភ្នំពេញ 1A-២១៧២ (ចាស់មិនប្រក្រតី) ទូរស័ព្ទដៃចំនួន០១(មួយ)គ្រឿងម៉ាក ០០០០ពណ៌ទឹកមាស(ចាស់បែកមិនដំណើរការ) និងកាបូបក្រវ៉ាត់ចង្កេះពណ៌ខ្មៅលាយក្រហមចំនួន០១ គប្បីតុលាការសម្រេចរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋ។

១១- សំណូមពររបស់ជនជាប់ចោទ៖

១១-១ ជនជាប់ចោទឈ្មោះ [redacted] លីនដា ហៅជ្រូក បានសំណូមពរអោយតុលាកាបន្ធូរបន្ថយទោសដល់ខ្លួនផង គប្បីតុលាការពិចារណា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] លីនដា និងផលវិបាកដែលនាំ អោយប៉ះពាល់ដល់សង្គមជាតិគប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លីនដា ចំនួន ០៦(ប្រាំមួយ)ឆ្នាំ។

១១-២ ជនជាប់ចោទឈ្មោះ [redacted] ប្រុសហ៊ីម បានសំណូមពរអោយតុលាកាបន្ធូរបន្ថយទោសដល់ខ្លួនផង គប្បីតុលាការពិចារណា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ប្រុសហ៊ីម និងផលវិបាកដែលនាំអោយប៉ះពាល់ដល់សង្គមជាតិគប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ប្រុសហ៊ីម ចំនួន ០៥ (ប្រាំ)ឆ្នាំ។

១១-៣ ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា បានសំណូមពរអោយតុលាកាបន្ធូរបន្ថយទោសដល់ខ្លួនផង គប្បីតុលាការពិចារណា អំពើរបស់ជនជាប់ចោទឈ្មោះ សោម ដារ៉ា និងផលវិបាកដែលនាំអោយប៉ះពាល់ដល់សង្គមជាតិគប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ចំនួន ០៥ (ប្រាំ)ឆ្នាំ និង០៦ (ប្រាំមួយ)ខែ ។

**ហេតុដូចនេះសាលាដំបូងកណ្តាល**

**វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ៖

១-១ ឈ្មោះ [redacted] លីនដា ហៅជ្រូក ភេទស្រី អាយុ២៨ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរៈចុងភៅ មានទីលំនៅបច្ចុប្បន្នភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ដាក់ពន្ធនាគារកំណត់រយៈពេល **០៦ (ប្រាំមួយ)ឆ្នាំ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល **តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។**

១-២ ឈ្មោះ [redacted] ប្រុសហ៊ីម ភេទប្រុស អាយុ៣៩ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរៈនេសាទ មានទីលំនៅបច្ចុប្បន្នភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ដាក់ពន្ធនាគារកំណត់រយៈពេល **០៥(ប្រាំ)ឆ្នាំ ពីបទ៖ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល **តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។**

[redacted]

១-៣ ឈ្មោះ [redacted] ដារ៉ា ភេទប្រុស អាយុ៤៣ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរៈជាងម៉ាស៊ីនត្រជាក់ មានទីលំនៅបច្ចុប្បន្នភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដាក់ពន្ធនាគារកំណត់រយៈពេល **០៥(ប្រាំ)ឆ្នាំ និង០៦(ប្រាំមួយ)ខែ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកហូរលិច១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល **តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។**

២- វត្ថុចាប់យករួមមានៈ

២-១ ម្សៅក្រាមពណ៌សថ្លាសង្ស័យជាសាធាតុញៀន ប្រភេទ(ម៉ាទឹកកក)ចំនួន១០(ដប់)កញ្ចប់ ធំ០៣កញ្ចប់ និងឧបករណ៍ប្រើប្រាស់ចំនួន០១ ដែកកេះ០១ គប្បីតុលាការសម្រេចរឹបអូសបំផ្លាញចោល ។

២-២ ម៉ូតូចំនួន០១(មួយ)គ្រឿង ម៉ាក់គ្រីអង្គរពណ៌ក្រហម ស្លាកលេខភ្នំពេញ ១A-២១៧២ (ចាស់មិនប្រក្រតី) ទូរស័ព្ទដៃចំនួន០១(មួយ)គ្រឿងម៉ាកoppoពណ៌ទឹកមាស(ចាស់បែកមិនដំណើរការ) និងកាបូបក្រវ៉ាត់ចង្កេះពណ៌ខ្មៅលាយក្រហមចំនួន០១ គប្បីតុលាការសម្រេចរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារឱ្យជនជាប់ចោទ។

ទុកសិទ្ធអោយប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កណ្ដាល,ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃទី 31 ខែ 3 ឆ្នាំ២០22

ក្រឡាបញ្ជី

[redacted]